# ធាតុចូលបឋមពីអង្គការសង្គមស៊ីវិល លើសេចក្តីព្រាងច្បាប់ភូមិបាល (ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៣)

## ថ្ងៃទី១៦ កុម្ភៈ ឆ្នាំ២០២៤

### ១- សេចក្តីផ្តើម៖

ក្រោយពីទទួលបានលិខិតស្នើធាតុចូលពីអង្គការសង្គមស៊ីវិល របស់ក្រសួងដែនដី នគរូនីយកម្ម និងសំណង់ កាលពីចុងខែមករា ឆ្នាំ២០២៤ អង្គការវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា បានដឹកនាំដំណើរការសម្របសម្រួលការប្រមូលធាតុចូលលើសេចក្តីព្រាងច្បាប់ភូមិបាល (ខ្លឹមសារសេចក្តីព្រាង ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៣) ជាមួយសមាជិក អង្គការដៃគូ និងតំណាងសហគមន៍ជាបន្តបន្ទាប់។ ការប្រមែប្រមូលធាតុចូល ត្រូវបានធ្វើឡើងតាមទម្រង់ផ្សេងៗដូចជា ការពិភាក្សាក្រុមតូចៗ ការពិនិត្យលើឯកសារផ្សេងៗ ជាពិសេសបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងគោលនយោបាយផ្សេងៗ និងតាមរយៈកិច្ចប្រជុំពិភាក្សា និងពិគ្រោះយោបល់ដោយផ្ទាល់ និងពីចម្ងាយ ក៏ដូចជាការដាក់ទម្រង់ទទួលមតិយោបល់តាមអនឡាញជាដើម។ ដំណើរការនៃការផ្តល់ និងទទួលធាតុចូលទាំងនេះ មានការចូលរួមពីសមាជិក អង្គការវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ក្រុមការងារបច្ចេកទេស អង្គការដៃគូថ្នាក់ជាតិ បណ្តាញអង្គការសម្របសម្រួលអង្គការមិនមែនរដ្ឋាភិបាលថ្នាក់ក្រោមជាតិ សហគមន៍នៅតាមមូលដ្ឋាន តំណាងក្រុមជនជាតិដើមភាគតិច និងអ្នកពាក់ព័ន្ធមួយចំនួនទៀត។ ក្នុងដំណើរការទាំងនេះដែរ ក៏មានកិច្ចសហការក្នុងភាពជាដៃគូ និងមានការចូលរួមពីតំណាងក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ផ្តល់ឱកាសចែករំលែក និងបំភ្លឺខ្លឹមសារច្បាប់ និងបញ្ហាផ្សេងៗ ក្នុងសិក្ខាសាលាពិគ្រោះយោបល់ កាលពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៤ កន្លងមកនេះ **ដែលមានអ្នកចូលរួមសរុប ១១០ នាក់ ស្ត្រី ២៨ នាក់ មកពី ៧៣ អង្គការ/ស្ថាប័ននៅទូទាំងប្រទេស** (ចូលរួមផ្ទាល់ចំនួន៥៦នាក់ ស្ត្រី ១៨នាក់ មកពី ៤០ អង្គការ/ស្ថាប័ន និងអ្នកចូលរួម តាមប្រព័ន្ធនិម្មិតចំនួន៥៤នាក់ ស្ត្រី ១០នាក់ មកពី ៥០ អង្គការ/ស្ថាប័ន)។

ជារួមខ្លឹមសារធាតុចូលទាំងនេះបានធ្វើឡើង ជាខ្លឹមសារបន្ថែម ការស្នើលុប/ដកចេញ ឬការកែប្រែ ស្របតាមសំណើ/សំណូមពរ និងមតិយោបល់ ព្រមទាំងមានខ្លឹមសារពន្យល់បន្ថែមលើសេចក្តីស្នើសុំទាំងនោះ។ ក្នុងនោះមានគំនិតស្នើឡើងជារួម និងជាក់លាក់ស្របតាមមាតិកា ជំពូក និងមាត្រា ដែលមានក្នុងសេចក្តីព្រាងច្បាប់ ព្រមទាំងគំនិតយោបល់ក្នុងការចូលរួមទប់ស្កាត់ និងដោះស្រាយបញ្ហា សម្រាប់ជាការពិចារណាដាក់បញ្ចូល ក្នុងខ្លឹមសារច្បាប់ឲ្យបានកាន់តែប្រសើរ ការអនុវត្តបាន និងមានប្រសិទ្ធភាព។ **ជាសរុបរួមមាន ធាតុចូលជាក់លាក់ចំនួន៨ជំពូក និងប្រមាណ ២៥ មាត្រា។ យោបល់ និងសំណើផ្សេងៗលើបញ្ហាជាក់លាក់ចំនួន២ ដែលមាន៥ចំនុច និង យោបល់ និងសំណើផ្សេងៗចំនួន៨ ចំនុច ព្រមទាំងការលើកពីបញ្ហានិងការវិវត្តន៍ចំបងៗពាក់ព័ន្ធពាក់ព័ន្ធ ដីធ្លីចំនួន៥។**

ដីធ្លី និងធនធានធម្មជាតិគឺជាអាយុជីវិតរបស់រដ្ឋ និងប្រជាពលរដ្ឋ។ សង្គមស៊ីវិលសូមកត់សំគាល់ និងសាទរចំពោះវឌ្ឍនភាពនៃការគ្រប់គ្រងដីនិងអចលនទ្រព្យជាច្រើនដែលរាជរដ្ឋាភិបាល ជាពិសេសក្រសួងដែនដី នគរូបនីយកម្ម និងសំណង់បានខិតខំកន្លងមក។ ឆ្លងតាមបទពិសោធន៍ និងរឿងរ៉ាវកន្លងមក មានបញ្ហាជាច្រើន ដែលបានកើតឡើង និងជួបប្រទះជាក់ស្តែង ដូច្នេះហើយយើងខ្ញុំជាសង្គមស៊ីវិលសង្ឃឹមថា ការផ្តល់ធាតុចូលទាំងនេះនឹងជួយពង្រឹងខ្លឹមសារនៃសេចក្តីព្រាងច្បាប់ភូមិបាលថ្មីនេះ ព្រមទាំងអាច

ចូលរួមទប់ស្កាត់ និងដោះស្រាយបញ្ហាបានកាន់តែប្រសើរ។ ជាពិសេស សូមស្នើជារួម មេត្តាជួយគិតគួរបន្ថែម ក្នុងខ្លឹមសារច្បាប់ លើការចូលរួមទប់ស្កាត់ និងបញ្ហាវិវត្តន៍សំខាន់ៗមួយចំនួនទៀតរួមមាន៖

- ការផ្ទេរស្ថានភាពនៃការប្រើប្រាស់ដីធ្លី (ឧទាហរណ៍ពីដីរដ្ឋ ទៅជាដីឯកជន ការផ្ទេរប្រភេទដីពីកសិកម្ម ទៅដីលំនៅដ្ឋាន ជាដើម)
- ការដោះស្រាយលើបញ្ហាដីធ្លី ជាពិសេសយន្តការដោះស្រាយ និងការផ្តល់សំណង
- ការប្រើប្រាស់ដីសម្ភហភាព និងដីសហគមន៍
- ការកសាងសំណង់ប្រភេទបុរី និងនគរូបនីយកម្ម
- ការកំណត់ដីសាធារណៈរបស់រដ្ឋ ជាពិសេសដីប្រឡាយ ផ្លូវទឹកផ្សេងៗ ពុំទាន់មានភាពច្បាស់លាស់ ដែលនាំឲ្យមានការទន្ទ្រានតាមរូបភាពផ្សេងៗ
- ផែនការប្រើប្រាស់ដី និងទិន្នន័យដីព្រមទាំងប្រព័ន្ធព័ត៌មានផ្សព្វផ្សាយអំពីដី និងផែនការប្រើប្រាស់ដីនៅទាំងមកម្រិតថ្នាក់ជាតិ និងក្រោមជាតិ
- គិតគូរពីយន្តការរដ្ឋបាល និងគ្រប់គ្រងកិច្ចការដី និងអចលនទ្រព្យ ដែលមានប្រសិទ្ធភាព ចំណេញពេលវេលា ចំណាយថវិកាតិច និងភាពដែលអាចជឿទុកចិត្តដ៏រឹងមាំបាន និងសុវត្ថិភាព។

## ២- តារាងធាតុចូលតាមជំពូក និងមាត្រា៖

| ល.រ | មាតិកា ជំពូក មាត្រាក្នុងសេចក្តីព្រាងច្បាប់ (ទំព័រ) | ខ្លឹមសារក្នុងសេចក្តីព្រាងច្បាប់ (ក្នុងជំពូក មាត្រា កថាខណ្ឌ) | ការស្នើកែប្រែ ឬ/និងសំណូមពរផ្សេងៗ | មតិយោបល់ ឬ/និង ខ្លឹមសារពន្យល់ |
|---|---|---|---|---|
| | **មាតិកាទី១**<br>**ជំពូកទី៣៖** | **គោលការណ៍** | | |
| 1. | មាត្រា៥ | | ស្នើបន្ថែមចំនុចលើគោលការណ៍ស្តីពី៖<br>- អភិរក្សតំបន់វប្បធម៌និងបេតិកភណ្ឌ ជនជាតិដើមភាគតិច<br>- គោរពសិទ្ធិមនុស្ស និង សិទ្ធិជនជាតិដើមភាគតិច | - តំបន់ទាំងនេះ ជាតំបន់វប្បធម៌ពិសេស ជាតំបន់ស្នូលនិងសម្បូរធនធានកម្រផ្សេងៗ ដែលគួរត្រូវបានការពារជាតំបន់អភិរក្សវប្បធម៌ និងបេតិកភណ្ឌ ជនជាតិដើមភាគតិច |

| ល.រ | មាតិកា ជំពូក មាត្រាក្នុងសេចក្តីព្រាងច្បាប់ ( ទំព័រ ) | ខ្លឹមសារក្នុងសេចក្តីព្រាងច្បាប់ (ក្នុងជំពូក មាត្រា កថាខណ្ឌ) | ការស្នើកែប្រែ ឬ/និងសំណូមពរផ្សេងៗ | មតិយោបល់ ឬ/និង ខ្លឹមសារពន្យល់ |
|---|---|---|---|---|
| | | | | - លើកកម្ពស់ឆន្ទៈច្បាប់ក្នុងការគោរព សិទ្ធិមនុស្ស ជាពិសេស សិទ្ធិជនជាតិ ដើមភាគតិច |
| | **មាតិកាទី២ ជំពូកទី១៖** | **គោលការណ៍ទូទៅនៃកម្មសិទ្ធិនិងសិទ្ធិផ្សេងទៀតលើអចលនវត្ថុ** | | |
| 2. | មាត្រា១៨ (ទំ.៦) | ចំណងជើងនៃមាត្រា៖ ការអនុវត្តក្រមរដ្ឋប្បវេណី | ស្នើប្តូរមកដាក់៖ ការអនុវត្តក្រមនីតិវិធីរដ្ឋប្បវេណី | |
| 3. | មាត្រា១៩ (ទំ.៦) | | មាត្រានេះជះឥទ្ធិពលលើបដិបញ្ញត្តិ។ សូមធ្វើការពិចារណាល្អិតល្អន់ តើគួរតែធ្វើការលុបចោលនូវបដិបញ្ញត្តិនេះ។ បដិបញ្ញត្តិនេះ វាអាចមានបញ្ហាច្បាប់ជាមួយនឹង មាត្រា១៩៨ នៃច្បាប់ភូមិបាលថ្មីនេះ។ | មាត្រានេះមានសារៈសំខាន់ណាស់ ដែលជះឥទ្ធិពលនៃបដិបញ្ញត្តិ ដូច្នេះហើយសូមពិនិត្យឡើងវិញពីបដិបញ្ញត្តិ នៃច្បាប់ ដែលអាចរងផលប៉ះពាល់ និងបង្កបញ្ហាផ្សេងៗ។ |
| | **ជំពូកទី២៖** | **កម្មសិទ្ធិសាធារណៈ** | | |
| 4. | មាត្រា២៤ (ទំ.៨) | | - រដ្ឋគួរតែកំណត់ជាក់លាក់ ពីនិយមន័យ នៃសម្បត្តិធម្មជាតិ និងកំណត់នូវ លិខិតបទដ្ឋានគតិយុត្តដែលមានកំណត់ដូចជាផ្ទៃនៃបឹង ឬទ្រព្យសម្បត្តិរដ្ឋ។<br>- រដ្ឋត្រូវកំណត់និយាមកាច្បាស់លាស់ ពីទំហំ និងគម្លាតនៃចំណីទន្លេ បឹង ស្ទឹងជាដើមដោយមានការចូលរួមពីសហគមន៍មូលដ្ឋាន។ | |

| លរ | មាតិកា ជំពូក មាត្រាក្នុងសេចក្តីព្រាងច្បាប់ ( ទំព័រ ) | ខ្លឹមសារក្នុងសេចក្តីព្រាងច្បាប់ (ក្នុងជំពូក មាត្រា កថាខណ្ឌ) | ការស្នើកែប្រែ ឬ/និងសំណូមពរផ្សេងៗ | មតិយោបល់ ឬ/និង ខ្លឹមសារពន្យល់ |
|---|---|---|---|---|
| 5. | មាត្រា២៥ | កថាខណ្ឌទី១ | ក្នុងកថាខណ្ឌទី១ នេះបានលើកឡើងតែពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ពុំអាចលក់ ដូរ ប្រទានកម្ម អច្ច័យទានជាដើម តែទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ពុំបានលើកឡើងនៅក្នុងមាត្រានេះឡើយ។<br>- ស្នើឱ្យថែងពីដីឯកជនរបស់រដ្ឋនៅក្នុងច្បាប់ភូមិបាលថ្មីនេះ ដូចក្នុងមាត្រា ១៧ នៃច្បាប់ភូមិបាល ឆ្នាំ ២០០១ និងកំណត់ផ្ទុយពីដីសាធារណៈរបស់រដ្ឋ គឺដីឯកជនរបស់របស់រដ្ឋ អាចជាកម្មវត្ថុ នៃការលក់ ការដូរ ប្រទានកម្ម អច្ច័យទាន ប្រាតិភោគ សម្បទានដី ការរឹបអូស ការរឹបអូសជាបណ្តោះអាសន្នបាន។ | ស្នើឱ្យមានការកំណត់ពីប្រទានកម្មទ្រព្យសម្បត្តិរដ្ឋ តើប្រទានកម្មនេះស្ថិតក្នុងអត្ថន័យបែបណា? ស្ថិតក្នុងរូបភាពបែបណាខ្លះ? ហើយត្រូវកំណត់ពីច្បាប់ពាក់ព័ន្ធដែលអាចយកមកប្រើក្នុងករណីប្រទានកម្មទ្រព្យរដ្ឋនេះ។ គួរមាននីតិវិធីប្រកបដោយអភិបាលកិច្ច តម្លាភាព និងគណនេយ្យភាពអំពីការដោះដូរ ឬលក់ដីឯកជនរបស់រដ្ឋ។ និងជាពិសេសមានការចូលរួមពិភាក្សាដេញដោលពីភាគីនីតិប្បញ្ញតិ និងប្រជាសហគមន៍ដែលពាក់ព័ន្ធ មុននឹងសម្រេចប្រើប្រាស់ ជាពិសេសការលក់ និងដូរដីឯកជនរបស់រដ្ឋ។ |
| | មាត្រា២៥ | កថាខណ្ឌទី៣ | - ការប្រើប្រាស់ពាក្យ **មិនទៀង** គួរមានកំណត់រយៈពេលអតិបរមានៃការប្រើប្រាស់ឲ្យបានសមស្រប<br>- វិសាលភាពនៃការបំពេញកាតព្វកិច្ចពន្ធ ដែលអាចប៉ះពាល់ ឧទាហរណ៍ ដីព្រៃ សហគមន៍ ឬដីរបស់រដ្ឋដែលប្រជាពលរដ្ឋកំពុងរស់នៅជាដើម។ | ដោយសារមានករណីខ្លះប្រជាពលរដ្ឋបានរស់នៅ និងប្រើប្រាស់លើដីឯកជនរបស់រដ្ឋច្រើនជាង១០ឆ្នាំ។ |
| | មាត្រា២៥ | កថាខណ្ឌទី៤ | - ខ្លឹមសារចុងក្រោយពីវិសាលភាពតំបន់ បេតិកភណ្ឌវប្បធម៌គួរមានលក្ខណៈជាក់លាក់ | - តំបន់ដែលកជាកម្មវត្ថុនៃការជួល គួរកំណត់ទំហំជាក់លាក់ ក្នុងការគ្រប់ដោយឯកជន ដើម្បីទុកឱកាសឱ្យសារណជនអាចប្រើប្រាស់ជាសារណៈ ឧទាហរណ៍តំបន់ភ្នំបូកគោជាដើម។ |

| ល.រ | មាតិកា ជំពូក មាត្រាក្នុងសេចក្តីព្រាងច្បាប់ (ទំព័រ) | ខ្លឹមសារក្នុងសេចក្តីព្រាងច្បាប់ (ក្នុងជំពូក មាត្រា កថាខណ្ឌ) | ការស្នើកែប្រែ ឬ/និងសំណូមពរផ្សេងៗ | មតិយោបល់ ឬ/និង ខ្លឹមសារពន្យល់ |
|---|---|---|---|---|
| | | | | - ការគិតគូរលើតំបន់បរិស្ថានធម្មជាតិ ដូចជាករណីភ្នំតាម៉ៅជាដើម |
| 6. | មាត្រា២៧ | | មិនបានបញ្ជាក់អំពី ការទទួលបាន កម្មសិទ្ធិ គួរបញ្ជាក់ឆ្នាំឲ្យបានច្បាស់លាស់ ក្នុងការកំណត់ប្រភេទព្រទ្យ សម្បត្តិសាធារណៈរបស់រដ្ឋ។ រយៈពេល ការតាំងទីលំនៅ គួរកំណត់ឆ្នាំដែលជាក់លាក់ដូចច្បាប់ភូមិបាលមុន (មុនខែសីហា ឆ្នាំ២០០១) | |
| 7. | មាត្រា៣០ (ទំ.១១) | កថាខណ្ឌទី១ | - សូមចែងឱ្យបានច្បាស់ពីការចេញប័ណ្ណ ដោយបានប្រព្រឹតរំលោភបំពាន | ករណីនេះអាចពាក់ព័ន្ធការទទួលខុសត្រូវរបស់មន្ត្រីបំពេញកិច្ច ក្នុងការចេញប័ណ្ណ និងត្រូវមានវិធានការរដ្ឋបាល ព្រមទាំងគិតគូរពីសំណងដល់បុគ្គលដែលរងគ្រោះពីការចេញប័ណ្ណប្រភេទនេះ។ |
| | មាត្រា៣០ (ទំ.១១) | កថាខណ្ឌទី៣ | - ការកម្រិតទោសគួរតែកំណត់ពាក់ព័ន្ធ ដំណើរការជូនដំណឹង ឧទាហរណ៍ ក្រោយការជូនដំណឹង ពីការអភិវឌ្ឍទើបមានទោស (ការជូនដំណឹង ត្រូវមានការប្រកាសជាសាធារណៈ)<br>- ការកម្រិតទោសត្រូវកំណត់ ឱ្យច្បាស់ថាជាទោស រដ្ឋប្បវេណី ឬទោសព្រហ្មទណ្ឌ<br>- ស្នើឲ្យមានទោសទណ្ឌជាក់លាក់ក្នុងការអនុវត្តលើជនល្មើស តើគួតែពិចារណាទៅលើ នីតិបុគ្គលដែលមានការ  ឃុបឃិតជាមួយជនល្មើស | ការជូនដំណឹងជាសាធារណៈឲ្យបានទូលំទូលាយ និងដោយតម្លាភាព ជួយលើកកម្ពស់ទំនុកចិត្ត ការចូលរួម និងការអនុវត្តកាន់តែមានប្រសិទ្ធភាព |

| ល.រ | មាតិកា ជំពូក មាត្រាក្នុងសេចក្តីព្រាងច្បាប់ ( ទំព័រ ) | ខ្លឹមសារក្នុងសេចក្តីព្រាងច្បាប់ (ក្នុងជំពូក មាត្រា កថាខណ្ឌ) | ការស្នើកែប្រែ ឬ/និងសំណូមពរផ្សេងៗ | មតិយោបល់ ឬ/និង ខ្លឹមសារពន្យល់ |
|---|---|---|---|---|
| | | | តើត្រូវបានដាក់បញ្ចូលនីតិវិធីនៃការអនុវត្តកម្រិតណា | |
| | មាត្រា៣០ (ទំ.១១) | កថាខណ្ឌទី៤ | គួរពង្រីកវិសាលភាពនៃសមត្ថកិច្ចឲ្យបានខ្ពស់ បន្តិចក្នុងការផ្តល់សិទ្ធិបណ្តេញជនល្មើស ឧទាហរណ៍ អាចជា តុលាការ | ត្រឹមអាជ្ញាធរមានសមត្ថកិច្ចថ្នាក់ក្រោមដូចជា អាជ្ញាធរមូលដ្ឋាន អាច មានលក្ខណៈ ផុយស្រួយ និងងាយចាប់បង្ខំពេក និងអាចបង្ករភាពចលាចលក្នុងសង្គម។ |
| | **ជំពូកទី៣៖** | **កម្មសិទ្ធិសមូហភាព** | | |
| 8. | មាត្រា៣៤ | | ការប្រើប្រាស់ពាក្យ ក្នុងជំពូក/មាត្រានេះ **ដីបញ្ញើសព** ចំណែកនៅមាត្រា ១៤៦ ប្រើពាក្យ **ដីកប់សព**។ តើគួប្រើពាក្យដូចគ្នា? ឬផ្សេងគ្នា ដែលបង្កប់ខ្លឹមសារផ្សេងគ្នា? | |
| 9. | មាត្រា៣៦ | កថាខណ្ឌចុងក្រោយ | ស្នើបន្ថែមក្នុងកថាខណ្ឌចុងក្រោយ៖ ការបង្កើតយន្តការថ្នាក់ក្រោមជាតិ ដើម្បីគាំទ្រ ការពារអចលនវត្ថុ រួមទាំង នីតិវិធី និងការទទួលស្គាល់ នីតិវិធី ចុះបញ្ជីដីសមូហភាពរបស់សហគមន៍ (វិធានការ ការពារបណ្តោះអាសន្ន)។ | កន្លងមកមានកង្វះខាតសេវាសាធារណៈ ថវិការដ្ឋ និងការជួយគាំទ្រ និងជួយសម្រួល ដល់ដំណើរការគ្រប់គ្រងអចលនវត្ថុ របស់ សហគមន៍។ ដូច្នេះ យន្តការនេះ នឹងជួយ ពន្លឿន និងធ្វើឱ្យមានការការពារដី សិទ្ធិ សហគមន៍ មិនឱ្យមានការលក់ដូរ ឬទន្ទ្រាន ពីអ្នកខាងក្រៅ ជាពិសេសធ្វើឱ្យសហគមន៍ មានសាមគ្គីភាព ហើយអាជ្ញាធរមូលដ្ឋាន បាន គ្រប់គ្រង និងគាំទ្រសហគមន៍ក្នុងការការពារ ធនធានធម្មជាតិនៅក្នុងតំបន់សហគមន៍។ |

| ល.រ | មាតិកា ជំពូក មាត្រាក្នុងសេចក្តីព្រាងច្បាប់ ( ទំព័រ ) | ខ្លឹមសារក្នុងសេចក្តីព្រាងច្បាប់ (ក្នុងជំពូក មាត្រា កថាខណ្ឌ) | ការស្នើកែប្រែ ឬ/និងសំណូមពរផ្សេងៗ | មតិយោបល់ ឬ/និង ខ្លឹមសារពន្យល់ |
|---|---|---|---|---|
| 10. | មាត្រា៣៧ | | ស្នើដាក់មកវិញអំពីនិយមន័យជនជាតិដើមភាគតិច ដែលមានក្នុងច្បាប់បច្ចុប្បន្នក្នុងមាត្រាទី២៣៖ សហគមន៍ជនជាតិដើមភាគតិច គឺជាក្រុមមនុស្ស ដែលរស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលសមាជិកទាំងអស់ បង្ហាញនូវការឯកភាព នៃជាតិពន្ធុ សង្គមវប្បធម៌ និងសេដ្ឋ កិច្ចប្រតិបត្តិ របៀបរស់នៅតាមប្រពៃណីនិងដាំដុះលើដី ដែលខ្លួន កាន់កាប់ទៅតាមក្បួនខ្នាត ទំនៀមទំលាប់នៃការប្រើប្រាស់ជាសមូហភាព។ | - មាត្រា២៣ ក្នុងច្បាប់បច្ចុប្បន្ន មានខ្លឹមសារជាក់លាក់ជាង ដែលងាយស្រួលក្នុងការកំណត់ ភាពជាសមាជិករបស់ជនជាតិដើមភាគតិច។<br>-ការកំណត់ខ្លឹមសារជនជាតិដើមភាគតិច គួរពាក់ព័ន្ធក្រុមអ្នកដែលគ្រប់គ្រងលើដី និងព្រៃយូលង់ណាស់មកហើយ។ |
| 11. | មាត្រា៣៨ (ទំ.១៣) | | ស្នើសរសេរបន្ថែម ដីសហគមន៍ ជនជាតិដើមភាគតិច ដែលមានដីចំនួន ប្រាំប្រភេទ គឺ៖ ដីលំនៅឋាន ដីកសិកម្ម ដីបម្រុង ដីកប់សព និងដីព្រៃអារក្ស។ | សហគមន៍ជនជាតិដើមភាគតិចមានដីចំនួន ប្រាំប្រភេទ ប៉ុន្តែនៅក្នុងមាត្រា៣៨ ឃើញតែដីលំនៅឋាន ដីកសិកម្ម និងដីបម្រុង ដោយពុំឃើញសរសេរអំពីដីកប់សព និងដីព្រៃអារក្ស |
| | មាត្រា៣៨ | កថាខណ្ឌទី២៖ | កថាខណ្ឌទី២៖ ស្នើបន្ថែម<br>...និង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត/ក្រុង។ | |
| | មាត្រា៣៨ | កថាខណ្ឌទី៣៖ | គួរបញ្ចូលដីសាធារណៈរបស់រដ្ឋផ្សេងទៀត ដែលសហគមន៍កំពុងប្រើប្រាស់តាម បែបប្រពៃណី សម្រាប់ អនុផលព្រៃឈើ និងកន្លែងប្រើប្រាស់ទឹក ជាសមាសធាតុ នៃដីសហគមន៍ជនជាតិដើមភាគតិច | - ធានាប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានធម្មជាតិ<br>- ធានានិងជួយការពារដីរដ្ឋ និងធនធានធម្មជាតិ ដោយសហគមន៍ នឹងមានភាពជាម្ចាស់ ហើយនិងជួយថែរក្សាធនធាន |

| ល.រ | មាតិកា ជំពូក មាត្រាក្នុងសេចក្ដីព្រាងច្បាប់ (ទំព័រ) | ខ្លឹមសារក្នុងសេចក្ដីព្រាងច្បាប់ (ក្នុងជំពូក មាត្រា កថាខណ្ឌ) | ការស្នើកែប្រែ ឬ/និងសំណូមពរផ្សេងៗ | មតិយោបល់ ឬ/និង ខ្លឹមសារពន្យល់ |
|---|---|---|---|---|
| | | | | ធម្មជាតិ យោងតាមបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍។ |
| 12. | មាត្រា៣៩ | កថាខណ្ឌទី១ | ស្នើបន្ថែម៖<br>គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋត្រូវបន្តត្រួតពិនិត្យតាមដាន និងការពារ នៅពេលមានការបំពានទាំងក្នុង និងខាងក្រៅ។ | |
| 13. | មាត្រា៤០ | កថាខណ្ឌទី១ | ស្នើលុបខ្លឹមសារចុងក្រោយ ដែលលើកឡើងពាក់ព័ន្ធបទដ្ឋានគតិយុត្តនានា។ ឬមានការកំណត់ឲ្យច្បាស់លាស់ សម្រាប់បទដ្ឋានគតិយុត្តណាដែលមាន ទំនាក់ទំនងសកម្មជាមួយខ្លឹមសារក្នុងកថាខណ្ឌ នេះ។ | |
| | មាត្រា៤០ | | ស្នើបន្ថែមចំពោះការសុំចូលជាសមាជិកសហគមន៍ដីដែលជាកម្មសិទ្ធិឯកជនរបស់ ខ្លួនដែលស្ថិតនៅក្នុងភូមិសាស្រ្តជាប់តំបន់សហគមន៍ត្រូវដាក់បញ្ចូលជាកម្មសិទ្ធិសមូហភាព | ជៀសវាងមានការភ័ណ្ឌច្រឡំ ករណីសមាជិកថ្មីមានដីឯកជន នៅឯឃុំ ឬស្រុកផ្សេង ហើយត្រូវបានទៀមទាឱ្យ ដាក់ដីនោះបញ្ចូលជាដីសមូហភាព។ |
| 14. | មាត្រា៤១ | កថាខណ្ឌទី១ | ស្នើបន្ថែមពាក្យ៖ អាជ្ញាធរ<br>-គ្មានបុគ្គល **និងអាជ្ញាធរ** ណាមួយ ក្រៅពីសមាជិកសហគមន៍ អាចទទួលបានសិទ្ធិលើ អចលនវត្ថុរបស់សហគមន៍ ជនជាតិដើមភាគតិចបានឡើយ។ | ការបន្ថែមពាក្យអាជ្ញាធរនេះ គឺផ្អែកលើច្បាប់បច្ចុប្បន្ន ដែលមានស្រាប់នៅក្នុងមាត្រា២៨ |
| | **ជំពូក៥** | **សម្បទានដី** | | |
| 15. | | សម្បទានដីសេដ្ឋកិច្ច | ស្នើសុំគិតគូរមតិយោបល់ដែលលើកឡើងដើម្បីដាក់ | - ស្នើសូមឲ្យខ្លឹមសារបន្ថែមទៅលើនិយមន័យដីសម្បទាន |

| ល.រ | មាតិកា ជំពូក មាត្រាក្នុងសេចក្ដីព្រាងច្បាប់ ( ទំព័រ ) | ខ្លឹមសារក្នុងសេចក្ដីព្រាងច្បាប់ (ក្នុងជំពូក មាត្រា កថាខណ្ឌ) | ការស្នើកែប្រែ ឬ/និងសំណូមពរផ្សេងៗ | មតិយោបល់ ឬ/និង ខ្លឹមសារពន្យល់ |
|---|---|---|---|---|
| | មាត្រា៥៩-៧៣ (ពាក់ព័ន្ធសម្បទានដីសេដ្ឋកិច្ច) | | បញ្ចូលក្នុងខ្លឹមសារនៃមាត្រា ក្នុងជំពូកនេះ និងបទដ្ឋានពាក់ព័ន្ធ៖<br>- ការកំណត់អត្តសញ្ញាណដី មុនការសម្រេចផ្ដល់ដី សម្បទានសេដ្ឋកិច្ច និងសម្បទានដីសង្គមកិច្ច គួរផ្ដល់ព័ត៌មានឱ្យបានគ្រប់គ្រាន់ ដល់ប្រជាពលរដ្ឋពិសេស សហគមន៍ជនជាតិដើមភាគតិច។ ព្រមទាំង ផ្ដល់ឱកាស ឱ្យពួកគាត់ចូលរួមពិគ្រោះយោបល់ឱ្យបានពេញលេញ និងយកមតិយោបល់ទៅពិចារណា ដើម្បីធ្វើការសម្រេចចិត្ត។ | - ធ្វើការសិក្សាលើផលប៉ះពាល់ និងពិគ្រោះយោបល់គ្រប់ភាគីពាក់ព័ន្ធ ឲ្យស្ថិតនៅក្រោមកម្រិតអតិបរមា<br>- ពិចារណាលើលទ្ធភាពដីសម្បទានសេដ្ឋកិច្ចដល់សហគមន៍ដើម្បីពួកគាត់មានលទ្ធផលក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចតាមគំរូរបស់ពួកគាត់ ដែលចូលរួមធានានូវនិរន្តរភាពសេដ្ឋកិច្ច សង្គម និងបរិស្ថាន។ |
| | | | - ការសម្រេចចិត្តផ្ដល់ដីសម្បទានសេដ្ឋកិច្ចគួរពិភាក្សា និង មានការបោះឆ្នោតផ្ដល់សេចក្ដីទុកចិត្តដោយរដ្ឋសភា។ | អ្នកដែលពាក់ព័ន្ធចូលរួមលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ត្រូវស្ដាប់មតិភាគច្រើន បើប៉ះពាល់ខ្លាំងមិនអាចអនុវត្តបានឡើយ |
| | | | - ដោយផ្អែកលើបូរណភាពទឹកដី ការផ្ដល់ដីសម្បទានសេដ្ឋកិច្ច នៅជាប់ព្រំដែនមិនត្រូវផ្ដល់ជូនជាតិសាសន៍ដែលស្ថិតនៅព្រំប្រទល់ដែនជាប់គ្នា និងមិនគួរលើសពីរយៈពេល ៣០ឆ្នាំ។ | |
| | | | - អាជ្ញាធរគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច គួរផ្ដល់ព័ត៌មាន បច្ចុប្បន្នភាព ដល់សាធារណៈជន ឱ្យបានដឹងអំពីវឌ្ឍនភាព បញ្ហាប្រឈម និងដំណោះស្រាយនានា រវាងអាជ្ញាធររដ្ឋ និងសម្បទាននិកនោះ។ គួរអនុញ្ញាតឱ្យ អង្គការសង្គមស៊ីវិលបាន ចូលរួមនៅក្នុង | |

| ល.រ | មាតិកា ជំពូក មាត្រាក្នុងសេចក្តីព្រាងច្បាប់ ( ទំព័រ ) | ខ្លឹមសារក្នុងសេចក្តីព្រាងច្បាប់ (ក្នុងជំពូក មាត្រា កថាខណ្ឌ) | ការស្នើកែប្រែ ឬ/និងសំណូមពរផ្សេងៗ | មតិយោបល់ ឬ/និង ខ្លឹមសារពន្យល់ |
|---|---|---|---|---|
| | | | កិច្ចប្រជុំនានា ពាក់ព័ន្ធនឹងការផ្តល់សម្បទានដីសេដ្ឋកិច្ច និងការត្រួតពិនិត្យ ការអនុវត្តការងាររបស់សម្បទានិក។ | |
| | | | -គួរមានអនុក្រឹត្យស្តីអំពីការអនុវត្តសម្បទានដីសេដ្ឋកិច្ច និងតម្រូវឱ្យ សម្បទានិក ផ្តល់សំណងការខូចខាត នានា ដូចជាការខូចខាតធនធានធម្មជាតិជាដើម ក្នុងករណីសម្បទានិក ពុំបានអនុវត្តនឹងត្រូវផ្តល់ដីសម្បទាន សេដ្ឋកិច្ចមករដ្ឋវិញ ដើម្បីធ្វើការជួលបន្ត ឬប្រើប្រាស់ ដើម្បីប្រយោជន៍សាធារណៈ។ | |
| | **មាតិកាទី៣**<br>**ជំពូកទី១៖** | **វិធាននៃដី** | | |
| 16. | មាត្រា៧៦ (ទំ.២៣) | កថាខណ្ឌទី១ | - ត្រូវមានកំណត់និយមន័យពីសិទ្ធិបុព្វក្រៃនេះ ហើយរដ្ឋចាំបាច់ ត្រូវមាន ការផ្សព្វផ្សាយជាមុនអំពីគម្រោង ឬ តំបន់អភិវឌ្ឍជាក់លាក់។ រដ្ឋគួរតែមានចែងជាក់លាក់ពីតួនាទី និងកាតព្វកិច្ច របស់រដ្ឋចៀសវាង ការរំលោភសិទ្ធិ និងធ្វើឱ្យប៉ះពាល់ ដល់សិទ្ធិ និងផលប្រយោជន៍ ដល់ប្រជាពលរដ្ឋ។<br>- រដ្ឋត្រូវផ្តល់ពេលវេលាសមស្រប និងគ្រប់គ្រាន់ ដល់ប្រជាពលរដ្ឋពីតំបន់អភិវឌ្ឍ។ | |

| ល.រ | មាតិកា ជំពូក មាត្រាក្នុងសេចក្តីព្រាងច្បាប់ (ទំព័រ) | ខ្លឹមសារក្នុងសេចក្តីព្រាងច្បាប់ (ក្នុងជំពូក មាត្រា កថាខណ្ឌ) | ការស្នើកែប្រែ ឬ/និងសំណូមពរផ្សេងៗ | មតិយោបល់ ឬ/និង ខ្លឹមសារពន្យល់ |
|---|---|---|---|---|
| | **មាតិកាទី៤**<br>**ជំពូកទី១** | **ផ្នែកទី៥៖ គណៈកម្មការសុរិយោដី** | | |
| 17. | មាត្រា១០៦ និង ១០៧ | | គណៈកម្មការសុរិយោដីដោះស្រាយវិវាទដីដែលពុំមានប្លង់កម្មសិទ្ធិ | |
| 18. | មាត្រា១០៩ | **កថាខណ្ឌទី១៖**<br>ក្នុងករណីមានបណ្តឹងទាមទារសិទ្ធិលើដីសាធារណៈរបស់រដ្ឋ ឬនីតិបុគ្គលសាធារណៈដទៃទៀត គណៈកម្មការសុរិយោដីត្រូវបដិសេធ សិទ្ធិកាន់កាប់ដីនោះ។<br>**កថាខណ្ឌទី២៖**<br>ក្នុងករណីភាគីម្ខាងជារដ្ឋ ឬនីតិ បុគ្គលសាធារណៈ ដទៃទៀត គណៈកម្មការសុរិយោដី ត្រូវសម្រេចទទួលស្គាល់ជាកម្មសិទ្ធិ របស់រដ្ឋ ឬនីតិបុគ្គលសាធារណៈ។ | - មុននឹងគណៈកម្មការសុរិយោដីធ្វើការបដិសេធនូវសិទ្ធិទាមទារសិទ្ធិលើដីសាធារណៈរបស់រដ្ឋ គណៈកម្មការសុរិយោដី ត្រូវធ្វើការស៊ើបអង្កេតឱ្យបានច្បាស់លាស់ថាដីនោះជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋ។<br>- ភាគីនៃអ្នកស៊ើបអង្កេតអាចត្រូវមាន សមាសភាពក្រៅពីភាគីរដ្ឋ។ | |
| | **ជំពូកទី២៖** | **ការចុះបញ្ជីដីធ្លីលើកដំបូង** | | |
| 19. | មាត្រា១២០ (ទំ.៣៦) | កថាខណ្ឌទី៣ | ស្នើបន្ថែមខ្លឹមសារ៖<br>ការចុះបញ្ជី និងចេញវិញ្ញាបនបត្រ សម្គាល់ម្ចាស់អចលនវត្ថុ ទៅឱ្យបុគ្គលក្រៅពីភោគី ត្រូវបានហាមឃាត់ និងត្រូវវផ្តន្ទាទោស ចំពោះអ្នកដែលចេញប័ណ្ណកម្មសិទ្ធិ និងអ្នកពាក់ព័ន្ធ។ | |

| ល.រ | មាតិកា ជំពូក មាត្រាក្នុងសេចក្តីព្រាងច្បាប់ (ទំព័រ) | ខ្លឹមសារក្នុងសេចក្តីព្រាងច្បាប់ (ក្នុងជំពូក មាត្រា កថាខណ្ឌ) | ការស្នើកែប្រែ ឬ/និងសំណូមពរផ្សេងៗ | មតិយោបល់ ឬ/និង ខ្លឹមសារពន្យល់ |
|---|---|---|---|---|
| 20. | មាត្រា១៨៥ | កថាខណ្ឌទី១ | បន្ថែមខ្លឹមសារពីអនុក្រឹត្យ ៨៣ ដែលលើកឡើងពីក្បាលដីស្នើសុំចុះបញ្ជីស្ថិតក្នុងវិសាលភាពនៃតំបន់ភូមិសាស្ត្ររដ្ឋបាលផ្សេងគ្នា ដែលជាប់គ្នាជាមួយតំបន់ភូមិសាស្ត្រសហគមន៍ | - ខ្លឹមសារមានស្រាប់ក្នុងអនុក្រឹត្យលេខ ៨៣ ដែលជាខ្លឹមសារសំខាន់ គួរដាក់បញ្ចូល<br>- ធានាសុខមាលភាពសង្គម ប្រពៃណី និងទំនៀមទំលាប់<br>- ពង្រឹងប្រសិទ្ធភាពគ្រប់គ្រងរបស់អាជ្ញាធរក្នុងតំបន់ |
| 21. | មាត្រា១៨៦ | | ទំហំដីបម្រុងទុកសម្រាប់ប្តូរវេនដំណាំ គួរផ្តល់ជូនសហគមន៍ទៅតាមការប្រើប្រាស់ជាក់ស្តែង នាពេលបច្ចុប្បន្ន ហើយបញ្ជាផ្ទៃក្នុង និងលក្ខន្តិកៈ របស់សហគមន៍ជនជាតិដើមភាគតិចត្រូវចែងអំពីការរក្សាការពារ និងបង្កើនគម្របព្រៃឈើ នៅក្នុងដីសម្រាប់បម្រុងទុកសម្រាប់ប្តូរវេនដំណាំ។ | ដីបម្រុងទុកសម្រាប់ការប្តូរវេនដំណាំបានដើរតួនាទីសំខាន់ ដល់ការបង្កើនគម្របព្រៃឈើ ហើយសហគមន៍ជនជាតិដើមភាគតិចនឹងអាចធ្វើជារបង ឬជាអ្នកជួយដល់ក្រសួងបរិស្ថានដែលមានអនុរក្សមានចំនួនកំណត់ ស្របពេលដែលថវិការដ្ឋនៅមានតិចតួចក្នុងការការពារព្រៃឈើ។ |
| | មាត្រា១៨៦ | ចំនុចទី២៖<br>ដីសាធារណៈរបស់រដ្ឋ | - ស្នើបន្ថែមប្រភេទដី ព្រៃសហគមន៍ ឬ សហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើ<br>- គួរមានអនុក្រឹត្យដាច់ដោយឡែក មួយទៀតពាក់ព័ន្ធចំការវិលជុំ និងដីបម្រុងទុកសម្រាប់ការប្តូរវេនដំណាំ ដែលគួរចុះបញ្ជីជូនសហគមន៍ទៅតាមការប្រើប្រាស់ជាក់ស្តែង ដើម្បីឱ្យសហគមន៍ធ្វើជារបងការពារធនធានធម្មជាតិ។ | ការផ្តល់ការចុះបញ្ជី និងការផ្តល់ប័ណ្ណកម្មសិទ្ធិ ដើម្បីធានាដល់ការគ្រប់គ្រង ដីសាធារណៈរបស់រដ្ឋ។ |

| ល.រ | មាតិកា ជំពូក មាត្រាក្នុងសេចក្ដីព្រាងច្បាប់ (ទំព័រ) | ខ្លឹមសារក្នុងសេចក្ដីព្រាងច្បាប់ (ក្នុងជំពូក មាត្រា កថាខណ្ឌ) | ការស្នើកែប្រែ ឬ/និងសំណូមពរផ្សេងៗ | មតិយោបល់ ឬ/និង ខ្លឹមសារពន្យល់ |
|---|---|---|---|---|
| | មាត្រា១៤៦ | កថាខណ្ឌចុងក្រោយ | ស្នើបន្ថែមខ្លឹមសារ ក្នុងអនុក្រឹត្យ អំពីទំហំដីកប់សព ឬដីព្រៃអារក្ស ដែលត្រូវកំណត់ ស្របតាមទំហំ ដែលមានការប្រើប្រាសើជាក់ស្ដែងរបស់សហគមន៍ | អាចស្នើដាក់បញ្ចូលនៅពេលមានរៀបចំអនុក្រឹត្យ |
| 22. | មាត្រា១៤៧ | កថាខណ្ឌចុងក្រោយ | គួរបន្ថែមខ្លឹមសារដែលបញ្ជាក់ពីការរៀបចំបទបញ្ជាផ្ទៃក្នុងសហគមន៍ ដែលត្រូវបានរៀបចំឡើងចាប់តាំងពីដំណាក់កាលមានការចងក្រងជាសហគមន៍ជនជាតិដើមភាគតិច។ | |
| 23. | មាត្រា១៥០ (ទំ.៤៥) | | មាត្រានេះគួរតែកំណត់ឱ្យច្បាស់ថារដ្ឋបាលសុរិយោដីកាន់កាប់វិញ្ញាបនបត្រម្ចាស់អចលនវត្ថុក្នុងករណីអ្វី? (ករណីលួច ឬបាត់ ឬពីអ្វី?) | |
| 24. | មាត្រា១៥១ (ទំ.៤៥) | | គួរតែបន្ថែមករណីរលុប ឬបាត់វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ដោយប្រការណាមួយ គួរតែអនុញ្ញាតឱ្យម្ចាស់អចលនវត្ថុធ្វើសារជាថ្មីឡើងវិញ។ | |
| | **មាតិកាទី៥៖** | **ទោសបញ្ញត្តិ** | | |
| 25. | មាត្រាទាក់ទងទោសបញ្ញត្តិ | | ស្នើសុំយកមាត្រា ២៦៥ នៃច្បាប់បច្ចុប្បន្ន | ខ្លឹមសារល្អ និងអាចជួយជម្រុញក្នុងការអនុវត្តច្បាប់ឲ្យកាន់តែមានប្រសិទ្ធភាព |

| ៣- សំណើ និងយោបល់លើបញ្ហាចំបងជាក់លាក់ ដែលស្នើគិតគូរពិចារណាលើខ្លឹមសារសេចក្តីព្រាងច្បាប់៖ | | |
| --- | --- | --- |
| **៣.១- ការផ្តល់សំណង** | ១- សំណងត្រូវផ្តល់ឱ្យដោយសមរម្យ និងយុត្តិធម៌។ ដូច្នេះហើយ រដ្ឋគួរតែធ្វើការបង្កើតឱ្យមានគណៈកម្មការឯករាជ្យ ដែលមានគ្រប់ភាគីពាក់ព័ន្ធក្នុងនោះ មាន រដ្ឋ អង្គការជាតិ ឬអន្តរជាតិ ជាដើម ដើម្បីចូលរួម ដោយតម្លាភាពក្នុងការវាយតម្លៃកំណត់អំពីសំណង។<br>២ - គោលការណ៍នៃការផ្តល់សំណង គួរតែមិនគិតត្រឹមការផ្តល់ជាថវិកាឡើយ គួរតែអាចជាការប្តូរទៅទីតាំងថ្មីដែលមានហេដ្ឋារចនាសម្ព័ន្ធ និងចម្ងាយសមស្រប (ឧទាហរណ៍មិនលើសពី៥គីឡូម៉ែត្រ ឬមានការព្រមព្រៀងជាក់ស្តែងពីម្ចាស់ដី) ក្នុងករណីដែលមិនអាចអភិវឌ្ឍនៅនឹងកន្លែង ឬធ្វើការអភិវឌ្ឍនៅនឹងកន្លែង ឬដោះស្រាយតាមគោលនយោបាយដទៃទៀត។<br>៣- រដ្ឋគួរបង្កើតយន្តការដោះស្រាយ សំណងដែលមានស្តង់ដាររួមមួយសម្រាប់ជាតិ បើទោះជាគម្រោងនោះជារបស់រដ្ឋ ឬជាគម្រោងឯកជន ដោយសិក្សា ស្រង់ យកបទពិសោធន៍ល្អៗដែលមានស្រាប់ និងបើកឱ្យមានការពិគ្រោះយោបល់ជាសាធារណៈ។ | |
| **៣.២- ការធ្វើអនុបយោគដីសាធារណៈរបស់រដ្ឋមកជាដីឯកជនរបស់រដ្ឋ** | ១- ស្នើសុំឱ្យការធ្វើអនុបយោគដីសាធារណៈរបស់រដ្ឋ មក ជាដីឯកជនរបស់រដ្ឋ គួរធ្វើឡើងដោយមានការប្រជុំដេញដោលនិងសម្រេចនៅក្នុងកិច្ចប្រជុំរដ្ឋសភា និងធានាយកសិទ្ធិអាស្រ័យផល និងជីវភាពរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានជាចម្បង។ | បើអាចសូមឲ្យមានការពិគ្រោះយោបល់ជាសាធារណៈជាមួយប្រជាពលរដ្ឋដែលរស់នៅជុំវិញ (អាស្រ័យផល) ដីសាធារណៈរបស់រដ្ឋ |
| | ២- ព័ត៌មាន ឬលទ្ធផល នៃកាធ្វើអនុបយោគដីសាធារណៈ របស់រដ្ឋនៅទីតាំងណាមួយ មកជាដីឯកជនរបស់រដ្ឋ គួរធ្វើការផ្សព្វផ្សាយជាសាធារណៈភ្លាមបន្ទាប់ពីការសម្រេចក្នុងការអនុញ្ញាតឱ្យ អនុបយោគពីរាជរដ្ឋាភិបាល។ | |

## ៤- យោបល់ សំណូមពរផ្សេងៗ និងសំណួរសម្រាប់ការពិចារណា សម្រាប់ជាធាតុចូលលើខ្លឹមសារ៖

៤.១ ការផ្ទេរកម្មសិទ្ធិដី គួរតែធ្វើនៅក្នុងនីតិវិធីដែលច្បាប់បានកំណត់ និងងាយស្រួល មានចំណាត់ការលឿន មិនតម្រូវឲ្យមានការរៀបចំក្នុងរយៈពេលដ៏យូរ ។

៤.២ អភិបាលកិច្ចរបស់មន្ត្រី ត្រូវពង្រឹងលើអាទិភាពរបស់អ្នកទទួលសេវា

៤.៣ ស្នើកំណត់ព្រំប្រទល់ដែន និងចំណីមាត់បឹង មាត់ស្ទឹង មាត់ទន្លេ សមុទ្រ ភ្នំ ផ្លូវ ឲ្យមានភាពច្បាស់លាស់។ ព្រមទាំងកំណត់និយមន័យភ្នំ ទួល កោះ ឲ្យបានច្បាស់លាស់ និងមានឯកសារបញ្ជាក់តំបន់ភូមិសាស្ត្រទំហំ ព្រំប្រទល់ សម្រាប់ប្រភេទតំបន់ទាំងនេះ។

៤.៤ ធ្វើយ៉ាងណាបង្កើតយន្តការ និងជម្រុញក្នុងការអនុវត្តច្បាប់ឲ្យកាន់តែមានតម្លាភាព និងមានប្រសិទ្ធភាពខ្ពស់

៤.៥ ការកំណត់ខ្លឹមសារពាក់ព័ន្ធការប្រើប្រាស់ដីធ្លី ដែលពាក់ព័ន្ធជាមួយផែនការមេសម្រាប់នគរូបនីយកម្ម

៤.៦ តើរដ្ឋបាលសុរិយោដីស្ថិតក្នុងតំបន់រដ្ឋបាលខេត្តផ្សេងគ្នា អាចផ្តល់បណ្ណកម្មសិទ្ធិលើដីសហគមន៍ជនជាតិដើមភាគតិចយ៉ាងដូចម្តេច? ក្នុងករណីនេះ សំណើមានមាត្រាថ្មី ដែលនិយាយអំពីការដាក់ពាក្យស្នើសុំទៅតាមគណៈកម្មាធិការរដ្ឋបាលសុរិយាដីពាក់ព័ន្ធក្បាលដី។

៤.៧ ឧទាហរណ៍៖ ករណីប្រជាពលរដ្ឋដែលទទួលបានការដោះស្រាយសំណងដោយប្តូរឱ្យទៅរស់នៅទីតាំងថ្មីហើយប្រជាពលរដ្ឋបានយលព្រមរស់នៅទីតាំងថ្មីដែលវាជាដីសាធារណៈរបស់រដ្ឋតាមការអនុញ្ញាតរបស់អាជ្ញាធរអស់រយៈពេលលើសពី ១០ឆ្នាំ តែក្រោយមកអាជ្ញាធរបានចោទសហគមន៍ថារស់នៅលើដីសាធារណៈរបស់រដ្ឋ ហើយមានបំណងឱ្យប្រជាពលរដ្ឋចេញពីទីតាំងដែលប្រជាពលរដ្ឋកំពុងរស់នៅនោះ តើរូបភាពដែលអាជ្ញាធរបានអនុញ្ញាតឱ្យប្រជាពលរដ្ឋរស់នៅនេះជារូបភាពប្រទានកម្មដែរឬទេ?

៤.៨ ឧទាហរណ៍៖ តើករណីនៅពេលដែលប្រជាពលរដ្ឋបានមករស់នៅទីតាំងជិតចំណីដីផ្លូវមួយអស់រយៈពេលជាយូរមកហើយលើសពី ១០ឆ្នាំ មុនច្បាប់ភូមិបាល និងលិខិតបទដ្ឋានគតិយុត្តនានាដែលកំណត់ពីចំណីផ្លូវត្រូវបានបង្កើតឡើង ក្រោយមកផ្លូវបានពង្រីក ហើយរដ្ឋបានកំណត់ពីទំហំចំណីផ្លូវ ដែលធ្វើឱ្យប្រជាពលរដ្ឋរស់នៅជិតផ្លូវនោះ ត្រូវបានអាជ្ញាធរថារស់នៅលើដីសាធារណៈខុសច្បាប់ (នៅលើដីចំណីផ្លូវ) តើករណីបែបនេះប្រជាពលរដ្ឋដែលរស់នៅជិតផ្លូវនោះរស់នៅលើដីសាធារណៈ ឬដីឯកជន?